Khmer Story Lovers

# បណ្ដាំមរណៈ

ទីតាំងការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៤៥ ជីឡូត៍លេខ ២៥៨ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
« មាតុភូមិ »
ភ្នំពេញ
លេខ ២៣

« បងរ៉ូ » បន្ត:

– បើមិនចង់ស្លាប់ត្រូវសម្ងំក្នុងទូក ។ លោកប្អូនស៊ុនទៅកាន់បន្ទប់ចុះ, មើល៍ យកកំណាត់ក្តារផ្តាប់កុំឲ្យគេឃើញ ។

ស៊ីផានបង្ខំនៅបាតទូកក្តាប់ទឹករលកបោកបក់ប្រាំពីរឡែរត្រឡប់ ។ នៅខាងលើ ក្រុមចោរដែកស្ងៀមក្នុងការភ័យខ្លាចឥតមាននរណានិយាយស្តីទៀតឡើយ ៗ បរិយាកាសស្ងប់ស្ងាត់បែបនេះ វាតែតេឲ្យមាណពអផ្សុក ខ្លោចចិត្ត រកនឹកស្មៀតគុនទាំងអស់ ដែលបានហាត់រៀនឡើងវិញលើកោះផ្សេងៗ ដើម្បីរំលាយចិត្ត ។

នាយស្រមៃដល់របៀបកាន់ដាវក្នុងដៃស្តាំ កាន់កាំបិតក្នុងដៃឆ្វេង, ស្មៀតបាប់ខ្លាំរបស់ចិន១ក្នុង១, ស្មៀតគុនរបស់ចិនមនក្បួន ម្តងមួយ ៗ ...

មិនយូរប៉ុន្មាន នាយមូលការម្នាក់បញ្ជូលកម្លាំងកាយមួយកន្លែង រកនឹកបន្ទោះណាដែលទន់ខ្សោយ ហក់ឡើងវិញក្នុងខួរក្បាលលុះត្រាយល់ជាក់ច្បាស់ ។ ដើមដំបូងនាយឈប់នឹកម្តងៗ ដើម្បីស្តាប់កិច្ចសន្ទនាលើក្បាល ឬស្តាប់ចលនាក្រុមចោរដែកខ្លះ, ដល់យូរទៅនាយផ្តកការម្នាក់លើបុគ្គសិល្បៈមួយមុខ លែងរវល់អ្វីៗនៅជុំវិញខ្លួនអស់រលីង ។

មាណពប្រមូលទាំងកម្លាំងកាយទាំងកម្លាំងប្រាជ្ញារំពឹកស្មោគគុនទាំងអស់ ពិចារណាស្រាវជ្រាវតាំងពីដើមដល់ចប់ ។ ពេលនេះហើយដែលកូនខ្មែរឥតពូជ ឬកាអន្សមដំក្លាយខ្លួនជាអ្នកក្លាហានមួយរូបគ្មានអ្វីបំភ័យក្នុងបណ្ដាអ្នកគុកទាំងមូលទៅ ។ ប៉ុន្មានខែក្រោយមក, នាយនឹកដល់កាយវិការប្ដីប្រពន្ធស៊ីឈើកាលប្រយុទ្ធជាមួយព្រាយរាន់ជាតក្នុងខ្ទមគញ្ចាស់, នឹកដល់ស្មៀនថ្មីៗ របស់ចិនម៉េងហួសមួន, ការប្រយុទ្ធលើកោះកៃផ្ស៊ែងក្នុងពេលថ្មីៗ . . . ដល់នឹកពិចារណាទៀតវិញនាយយល់ច្បាស់លាស់ទាំងអស់គឺសប្បាយពេញចិត្តលបញញឹមម្នាក់ឯង ។

ពេលដែលនាយកំពុងបណ្ដែតអារម្មណ៍ទៅកាន់ពិភពគុកនោះនាយឮប្រកាក់ៗ គឺទូករសេបជិតដល់ច្រាំងហើយ ។ "លោកបង្រួ" ស្រែកបញ្ជា:

– ពួកយើងនាំគ្នាចូលក្នុងផ្ទះឲ្យអស់ហើយកុំចេញក្រៅទៀតណា ! ត្រូវចាំបញ្ជាលោកនាយក្រុមសិន ។

អ្នកឯទៀតឆ្លើយតបតិចៗ ហើយនាំគ្នាឡើងលើគោកយ៉ាងស្ងៀមស្ងាត់ ។ ស៊ិផាន សម្ងំជាមួយសន្ទះដែលគេចេញពីទូកអស់ហើយ ទើបនាយបើកគំរបបុបទូកចេញមកពីគេវិញ ។

ពេលនេះថ្ងៃត្រង់ជាក់ នាយស្រវាំងភ្នែកមួយស្របក់ទើបត្រាច្បាស់មើលទេសភាពស៊ីវិញ ។ ស្ងាត់ស្ងួត! នាយលួចដើរៗ ចេញពីកន្លែងទូកស្កាត់សព្រុំព្រៃនៃកោះដដែល ។

នាយរើសកាំបិតស្នៀតបន្តើរហើយកាប់ឈើខ្ទាងយកស្រោកស្លាប់ខ្ទះទុកចំណីអាហារ ។ រួចរាល់ហើយ ទើបនាយដើរកាត់ច្នុចតម្រង់កន្លែងចូលលោតទៀងគោកប៉ោងស្រាល ។ នាយដើរសសៀរតាមមាត់ទឹកបានប្រហែលមួយយោជន៍ ទើបហ៊ានដើរតាមផ្លូវធំព្រមទាំងនឹកថា :

– មើលទៅបែបមិនទាន់ផុតគ្រោះប៉ុន្មានទេ , ត្រូវតែគេចខ្លួនឲ្យប្រញាប់ ។

មាណពគិតឃើញផ្លូវប្លែកតែឥតហ៊ានឆ្លងកាត់ក្រោយ ។ ក្នុងខេត្តនេះស្ងាត់ស្ងៀមឥតមានផ្ទះអ្នកស្រុកសោះទេ ម៉្លោះហើយប៉ុន្មានតែតាមផ្លូវគេជួបអ្នកដំណើរមួយនាក់ឡើយ ។

ការពិតនាយឥតដឹងសូម្បីបន្តិចឡើយ ។ ព្រោះកោះនេះពីដើមមានផ្ទះអ្នកស្រុកដែរ តែក្រុមចោរដែលបង្កប់ធ្វើបាបពុលសាប់អស់គ្មានសល់ ។ អ្នកមកពីខាងបង ។ ដល់ពានត្រូសារមកនៅមិនបានប៉ុន្មានក៏ពុលស្លាប់ដែរ គេនិក មិនខេត្តនេះ ម ពបន្ទោះក្ដុម ឈ្មោះ ទើបអ្នកដំណើរក ចៀសវាងមិន

ប្រាំបីឆ្នាំកន្លងមក ហើយដែលក្រុមប្លុកដែកសាបព្រោះអំពើអមនុស្សធម៌បណ្ដាញអ្នកស្រុក ដើម្បីកាន់ឲ្យតំបន់តូចនេះឲ្យទៅជាជំរកសម្ងាត់សំរាប់ក្រុមបក្សពុកពួករបស់ខ្លួន ។

ស៊ីផានតែបានឆ្ងាយទៅៗ តែត្រាំនឹងការស្រេកឃ្លានតទៅទៀតមិនបាន ក៏គេចចូលព្រៃមួយគ្រាស់ដើម្បីរកបេះផ្លែឈើបរិភោគសិន ។ ដើរមិនទាន់ដល់កណ្ដាលព្រៃមែនទែនផង ស្រាប់តែឃើញជ្រូកមួយស្ទុះចេញមកសន្ធប់នាយតែម្ដង ។

ស៊ីផានលែងល្ងង់, លែងយឺតយ៉ាវហើយ ! នាយផ្អៀងខ្លួនគេចបន្តិច ហើយដកកាំបិតពីចង្កេះសម្ដែងស្នៀតត្រានព្រៃកាប់អុស នៃក្រុមព្រះអាទិត្យសំពងកូសដាច់ក្បាលជ្រូកព្រៃរមៀលដល់ដី ! ជ្រូកនេះមានកម្លាំងសម្បើមណាស់ ដាច់ក្បាលហើយនៅហក់ផ្លោះទៅមុខពីរបីព្យាមទៀតទើបដួលស្លាប់ ។ ស៊ីផានរីករាយណាស់ រៀបចំបង្កាត់ភ្លើង ហើយកាប់ជើងជ្រូកទាំងបួនបោចរោមយកទៅលាងទឹកឲ្យស្អាតកាច់មែកឈើដោតអាំងភ្លាម ។ មួយសន្ទុះក្រោយមក ជើងជ្រូកហុយក្លិនឈ្ងុយឈ្ងប់គួរស្រក់ទឹកមាត់ ។ ពេលដែលកំពុងបង្វិលជើងជ្រូក ស្រាប់តែឮសម្លេងពីគុម្ពោតព្រៃឯនាយថា :

-ឈ្ងុយណាស់, ឆ្ងាញ់ណាស់ ! គួរឲ្យរមួលពោះមែន !

សម្លេងមួយទៀតបន្ត :

-ប្រហែលមាននរណាអាំងសាច់ក្ដាន់ព្រៃហើយ យើងរកទៅសុំចែកពីគេខ្លះទទួលទានម្ដ ?

សម្លេងទីមួយយល់ស្រប :

-មែន ! ទៅ !

ឮស្នូរជើងជាន់ស្លឹកឈើព្រោកព្រាក ៗ...

ជនម្នាក់មាឌធំធាត់ មុខមូល ត្រចៀកធំ ពាក់អាវពណ៌លឿង មុខស្រស់ញញឹមជាប់គួរឲ្យរាប់អាន, អ្នកស្គមខ្ពស់ពាក់អាវពណ៌ផ្ទៃមេឃមានពុកមាត់ខ្ទីៗ មុខស្ងៀមមិនញញឹមមិនក្រញូវ ។ ជនធាត់ធំសើចហាស់ហា ! សួរមាណព :

ប្អូនប្រុស , ឯងកំពុង . . .

ស៊ីផានឆ្លើយគាត់ :

-ខ្ញុំមានសាច់ជ្រូកព្រៃច្រើនណាស់, ទទួលទានដប់នាក់ក៏មិនអស់ដែរ , សូមលោកទាំងពីរអញ្ជើញពិសាតាមត្រូវការ ។

ជនកន្លាត់សើចញឹមៗ:

– អ! បើបានអ៊ីចឹងយើងសុំអរគុណប្អូនច្រើនណាស់ ។

មុសេតាំងពីដាក់បង្គុយប៉ុកក្បែរគ្នក់ភ្លើង ។ គេសង្កេតឃើញស៊ីផានស្លៀកពាក់ខោការ ខានតម្លៃតែរហែកផងប្រឡាក់ឈាមផងគឺបញ្ចេញចំកមុខជើងដល់រៀងខ្នង ។ មួយស្របក់នេ ង៉ាកទៅសំឡឹងជើងជ្រូកវិញឃើញកំពុងតែស្រក់ខ្លាញ់តក់ៗលើភ្លើងឆេះឆៅៗ ធុំក្លិនឈ្ងុយឡើងៗ ធ្វើឲ្យអ្នកតាំងបីលេបទឹកមាត់ក្អឿកៗ ។

ជនមាឌខ្ពស់ស្គមស្រាយសំបកឃ្លោកពីក្រោយខ្នង បើកឆ្នុកងើយផឹកមួយក្អឹក ពោលសរសើរថា:

ស្រានេះឆ្ងាញ់ណាស់ ។

ជនធាត់ធំ ក៏ស្រាយឃ្លោកគាត់ពណ៌ក្រហមពីចង្កេះមកក្រឡុក រួចបើកឆ្នុកផឹកមួយក្រេបដែរ:

– ឆ្ងាញ់ណាស់ ! ស្រាខ្ញុំឆ្ងាញ់មែន !

ស៊ីផានស្គាល់រស់ជាតិស្រា កាលដើរជាមួយសែយានទី, ឥឡូវឃើញគេផឹកនឹងមុខនឹងមាត់ ថែមទាំងធុំក្លិនក្រអូបឈ្ងុយឈ្ងប់ផង ក៏ចង់ផឹកឲ្យខ្លួនម្ដង តែមិនហ៊ាននិយាយព្រោះជនទាំងពីរហាក់គ្មានចិត្តហៅខាយសោះ ។ មួយសន្ទុះក្រោយជើងជ្រូកទាំងបួនឆ្អិនក្រហមរលោងហាក់ស្រួយឆ្ងាញ់ណាស់ ។ ស៊ីផានស្រែក:

– ឆ្អិនហើយ, សូមអញ្ជើញពិសា ។

ជនសំគមនិងកន្លាត់លូកដៃព្រមគ្នាយកជើងជ្រូកធំៗម្នាក់មួយ រៀបហាមាត់ក្រហាក់ទៅហើយ ស្រាប់តែស៊ីផានសើចញឹមៗពោល:

– ជើងទាំងពីរនេះធំមែនព្រោះសុទ្ធជាជើងក្រោយ, ប៉ុន្តែឆ្ងាញ់មិនដល់ជើងមុខទេ ។

ជនកន្លាត់សើចហេសៗ:

– អាប្រមក់ឯងចិត្តល្អគ្រាន់បើ ។

ពោលបណ្ដើរប្ដូរយកជើងមុខមកទទួលទានវិញ ។ ចំណែកជនសំគមក្រញាក់មួយម៉ាត់ហើយ ទើបមិនប្ដូរនឹងគេទេ ។ គេចំពារជើងជ្រូកពីរបីម៉ាត់បើកឆ្នុកឃ្លោកស្រាក្រេបមួយក្អឹកទៀតលាន់មាត់:

– ឆ្ងាញ់ណាស់, ឆ្ងាញ់ណាស់ ។

រួចគេបិទឆ្នុកក្បូរនឹងបន្ទះទុកវិញ ។ មាណពនឹកក្នុងចិត្តថា :

– ជនពីរនាក់នេះមិនមែនក្រីក្រប៉ុន្មានទេឡើយ, ម្តេចកំណាញ់ម្ល៉េះ, ផឹកមួយក្រេបទុកមួយ . . . ឬមួយស្រាគេថ្លៃហួសហេតុកម្ររកទិញ ?

នាយធ្វើជានិយាយទៅកាន់ជនកន្ទាត់ :

– ខ្ញុំសុំផឹកពីរបីក្រេបផង បានទេ ?

ជនកន្ទាត់គ្រវីក្បាល :

– មិនបានទេ , មិនកើតទេ ។ មិនមែនស្រាឯណា ? យើងទទួលទានដើម្បីផ្លូវឯង , បន្តិចទៀតត្រូវឲ្យគ្នាឯងជាបាច់ ។

មាណពញញឹម :

– លោកប៉ុនកុហកមែនហ្ន៎ ! អម្បាញ់មិញលោកពោលបញ្ជាប់ស្រុកថាស្រាឆ្ងាញ់ ។ ! ខ្ញុំក៏ក្ទុនស្រាដែរ ។

នាយងាកទៅសួរជនស្គមម្ខាង :

– ចុះលោកខាងណោះចែកខ្ញុំទទួលទានផងបានទេ ?

ជននោះបើកភ្នែកក្រឡេត :

– នេះជាថ្នាំពុលទេតើ ! បើឯងមិនខ្លាចស្លាប់ផឹកចុះ !

ពោលចប់គាត់ស្រាយឃ្លោកពីចង្កេះហុចឲ្យស៊ីផាន ។ មាណពទទួលឃ្លោកហើយតបថា :

– បើពិតជាថ្នាំពុលមែន, ហេតុអីលោកមិនស្លាប់ ?

ពោលសួរផងនាយបើកឆ្នុកផងធុំក្លិនស្រាក្រអូបឆ្ងុលច្រមុះ ។ ជនកន្ទាត់ញ៉ោះទឹកមុខស្រែកឃាត់ :

– យើងមិនកុហកឯងទេ , កុំផឹក !

គាត់លូកដៃប្រុងកញ្ឆក់ឃ្លោកមកវិញ ។ គ្រាន់តែប៉ះដៃមាណពភ្លាមក៏មានកម្លាំងសម្ពាត់ផ្ទាត់គាត់ខ្ទាតចេញវិញភ្លាម ។ ជនកន្ទាត់លាន់មាត់: យី ! ពួកយើងព្រិលភ្នែកទេ, អញ្ចឹងពិសាចុះ ។

ស៊ីផានលើកឃ្លោកចាក់ស្រាអកក្អឹកៗ ពីរម៉ាត់យ៉ាងធំ ព្រមទាំងនឹកថា :

-ជនសំគមនេះចូលចិត្តផឹកស្រា តែមិនដាច់ចិត្តផឹកច្រើនទេ, ហើយកុំផឹករបស់គេច្រើនពេក ។ នាយប៉ិចទុកវិញប្រគល់ឲ្យជនសំគមពោលថា:

- សូមអរគុណច្រើន !

មួយរំពេចនោះស្រាប់តែមានធាតុម៉្យាងត្រជាក់ស្រេបតែសើបក្នុងកាយនាយ បណ្ដាលឲ្យរឹងខ្លួនយ៉ាំងតាន់ហាន់ ។ ស៊ីផធានភ្ញាក់ព្រើតម្ដីម្ចាប់រើនកម្លាំងទប់ទល់ភ្លាម ៗ មួយស្របក់ធំទើបនាយបង្ក្រាបធាតុត្រជាក់បាន,គំរើកដៃជើងដោយស្រួលថែមទាំងមានធាតុក្ដៅឧណ្ហៗសព្វកន្លែងផង ៗ នាយពោលសរសើរភ្លាម :

- ស្រានេះឆ្ងាញ់មែន ! .. ខ្ញុំមិនដែលបានស្គាល់ជាតិទេ តែ... គួរស្ដាយណាស់ដោយ ហេតុស្រាលោកថ្លៃពេក,បើពុំនោះទេខ្ញុំក្រេបអស់មួយឃ្លោកហើយ !

បុរសធាត់ទន់ស្ដួមព្រហ្មហានេះ នាំគ្នាបញ្ចេញទឹកមុខស្ញើងឆ្ងល់យ៉ាំងខ្លាំង ៗ ផងកន្ទាត់បន្ទរថា :

- អីប្អូនប្រុស , បើចូលចិត្តផឹកស្រាមែន , សូមផឹករបស់ខ្ញុំទាំងអស់ចុះ ៗ

មាណពសួរទាំងត្រេកអរ :

- មែនឬ ? តែក្រែងលោកខាងណោះមិនដាច់ចិត្តណា !

ជនសំគមឆ្លើយគំកេះគំរើយ :

- ឃ្លោកក្រហមលោកបងខាងណោះជាស្រាពិប មានរសជាតិឆ្ងាញ់ជាងស្រាយើងថែមទៀត, ឯងចង់ភ្លក្សទេ ?

មាណពសម្លឹងមុខជនកន្ទាត់ក្នុងន័យអង្វរគេ , ជននោះដកដង្ហើមធំ :

-នៅក្មេងនោះមានកម្លាំងធាតុស្អុកស្អុកយ៉ាងនេះមិនគួរស្លាប់អសារឥតការទេ ! ស្ដាយណាស់, គួរស្ដាយណាស់ !

ពោលបណ្ដើរ គាត់ស្រាយឃ្លោកពីចង្កេះមកដាក់ចំកណ្ដាល ៗ ស៊ីផធានសញ្ជឹងគិតថា តើនាក់នេះចូលចិត្តកំប្លែងលេងទេដឹង ? បើស្រាពុលមែន, ហេតុអ្វីគេហ៊ានផឹក ?

នាយលូកយកឃ្លោកក្រហមមកបើកឆ្នុកភ្លាម ធុំក្លិនស្រាក្រអូបហួង, នាយលើកអកក្អឹក ៗ.....

មួងនេះហាក់មានកំសួលភ្លើងឆេះឆ្លលក្នុងពោះ នាយស្រែកអូ ! ស្ទុះលោតក្រោតបម្រើនកម្លាំងធាតុពន្លត់កំសួលភ្លើងនោះភ្លាម ហើយស្រែកខ្លាំងៗ:

- ស្រានេះអស្ចារ្យមែន !

គួរឲ្យឆ្ងល់ណាស់ គ្រាន់តែសំរួលក្លិនរលត់ ពាក្យក្ដៅលោយ នាយចាប់ការម្ចាស់ដូចស្រួលខ្លួនខុសធម្មតា ។ ផនសង្កត់បន្ថែមថា:

- កម្លាំងជាតុឯងវិសេសវិសាលបែបហ្នឹង ហេតុអ្វីមិនផឹកឲ្យអស់ទៅ ?

ស៊ីផាន់សើចញឹមៗ :

- ខ្ញុំផឹកម្នាក់ឯងមិនសមរម្យទេ ព្រោះថ្ងៃនេះយើងទាំងបីបានជួបជុំគ្នាដូចមិត្តសម្លាញ់ គួរតែផឹកម្នាក់មួយផ្តិល,ស៊ីម្នាក់មួយដុំទើបប្រសើរ ។ ធ្វើដូច្នេះមិនសប្បាយជាង ? សូមអញ្ជើញ !

ពោលរួច ក៏ហុចឃ្លោកស្រាម្ចាស់ដើម ។ ផនក្អាត់សើច :

- ប្អូនប្រុសចង់សាកល្បងជាមួយយើង យើងត្រូវតែជួយកំដរ ។

គាត់ទទួលយកឃ្លោកមកផឹកមួយផ្តិល ហើយហុចទៅឲ្យមាណពវិញដោយស្រដីថា:

- សូមប្អូនប្រុសផឹកទៀតទៅ !

ស៊ីផាន់ផឹករួច, ហុចឃ្លោកឲ្យផនសំគម :

- សូមលោកខាងណោះអញ្ជើញ !

ផនសំគមប៉ោះទឹកមុខ ប្រកែក :

- យើងផឹករបស់យើងបានហើយ ។

-គាត់លើកយកឃ្លោកពណ៌ទៀត, អកមួយក្រេបហើយ ហុចឲ្យមាណព ។ ស៊ីផាន់ពិតជា បើផឹកក្ដៅ និង ក្រឡាក់លាយគ្នាប្រហែលមានខ្លាំងសណ្ឋាយខ្លាំងណាស់ ម្ល៉ោះហើយនាយទទួលយកឃ្លោកពណ៌ទៀតអកក្អឹក ៗ ក្លាម ។ នាយឃើញផនសំគមនិងផនក្អាត់បើកភ្នែកធំ ៗ សម្លឹងមើលខ្លួន ក៏ភ្ញាក់ព្រើត បញ្ចេញទឹកមុខអៀនប្រៀន:

- សូមអត់ទោស ! លើកនេះខ្ញុំផឹកច្រើនពេកហើយ ។

ផនសំគមពោលយ៉ាងសោះកក្រោះ :

- បើឯងចង់ទុកខ្លួនជាអ្នកក្លាហាន អញ្ជើញផឹកទៅទៀតចុះ ! ផឹកច្រើនកាលណាប្រសើរទៀងកាលនោះ !

មាណពញញឹមញញែម :

-បើមិនទាន់ស្កប់ស្កល់ទេ គួរយើងទៅទីប្រជុំជនខាងមុខទិញស្រាមួយផុចធំ ផឹកឲ្យអស់ចិត្តអស់ចង់ម្ដង ៗ ប៉ុន្តែខ្ញុំខ្លាចក្រែងគ្មានស្រាល្អដូច្នេះណា !

ពោលចប់ ក្រេបស្រាក្នុងពែងក្រហមមួយក្អឹក ហើយហុចឲ្យជនកន្លាត់ ។ ជននេះតែងតែចម្រើនកម្លាំងធាតុមួយសន្ទុះទើបលើកពែងផឹកមួយក្អឹក ។ គាត់ឃើញអ្នកកម្លោះលេបស្រាយ៉ាងស្រួលដូច្នេះតឹងទ្រូងឆ្ងល់ខ្វល់ជ្រួលភ្ញាក់ភ័យជាខ្លាំង ។

ជនចម្លែកទាំងពីរសុទ្ធសឹងជាអ្នកក្លាហានដ៏ខ្លាំងពូកែកម្រកេបាន តែយុទ្ធសិល្បៈម្នាក់ៗ មានភាពខុសប្លែក គឺជនកន្លាត់មានស្នៀតគុនកាចសាហាវនិងខ្លាំងក្លារឹងប៉ឹង ឯជនសំគមទន់ភ្លន់ ។

ចំណែកពែងរបស់គេមានដាក់ស្រាថ្នាំសម្រាប់ជួយលើកស្ទួយកម្លាំងធាតុ ។ ក្នុងពែងក្រហមគឺជាតិថ្នាំក្ដៅ ឯក្នុងពែងខៀវជាតិថ្នាំត្រជាក់ ។ ស្រាទាំងពីរមុខមានបញ្ចូលថ្នាំពិសេសៗជាច្រើន ដែលអ្នកទាំងពីរខំដើររកសង្ស្រមកផ្សំទម្រាំតែបាន គឺពិតជាស្រាថ្នាំដ៏ខ្លាំងហើយចំពោះជនណាដែលមានកម្លាំងធាតុអន់ខ្សោយពេកចាត់ទុកជាថ្នាំបំពុលដ៏សាហាវបំផុតផង ព្រោះបើហ៊ានលេបមួយតំណក់ពីប្រាកដជាក្ស័យណក្ស័យមិនខាន ។

ជនសំគមនិងជនកន្លាត់មានកម្លាំងកាយស្ទុកស្ទម្ភក្រៃលែង តែម្នាក់ៗសឹងបានលេបថ្នាំចន្សាបរួចផង ទើបហ៊ានអកប្អូនប្រាំក្អឹក ហើយប្រសិនបើជនកន្លាត់ច្រឡំផឹកស្រាត្រជាក់ ឯជនសំគមច្រឡំស្រាក្ដៅ ច្បាស់ជារមួលពោះវៀនចេញឈាមគ្រប់ពេលស្លាប់យ៉ាងខ្លោចផ្សាមួយរំពេច ។

កាលបើឃើញមាណពផឹកក្អឹកៗធ្វើព្រងើយដូច្នេះ មិនឲ្យគេភ្ញាក់ភ័យម្ដេចកើត ?

អ្នកទាំងពីរថ្វីត្បិតតែមានការពិសោធច្រើន ជួនទន្ទឹងយល់ព្រឹត្តិការណ៍ក្នុងពិភពគុនស្ទើរគ្មានចន្លោះ តែមិនធ្លាប់ប្រទះយុវបុរសណាមានភព្វព្រេងសំណាងបានហាត់រៀនយុទ្ធសិល្បៈកម្លាំងធាតុត្រជាក់ប្រហាក់ប្រហែលកម្លាំងធាតុក្ដៅដូច្នេះឡើយ

នេះជាព្រឹត្តិការណ៍មួយដ៏ចម្លែកនៃពិភពគុន គឺអ្នកកម្លោះបានហ្វឹកហ្វឺនយុទ្ធសិល្បៈកម្លាំងធាតុត្រជាក់ដែលទន់កាលពីក្មេង ហើយក្រោយមកបានហាត់វិជ្ជាក្ដៅខ្លះៗ របស់សៃយានទីទៀត ។ យុទ្ធសិល្បៈទាំងពីរមានភាពផ្ទុយគ្នា គឺមួយត្រជាក់ មួយក្ដៅ គួរណាស់មាណពទទួលគ្រោះថ្នាក់ដល់ជីវិត តែមិនដូច្នេះត្រឡប់ជាមានមូលដ្ឋានកម្លាំងធាតុដ៏កំពូលទៅវិញ ។ ក្រោយមកនាយហាត់ហ្វឹកហ្វឺនយុទ្ធសិល្បៈព្រះរូបបង្ក្រាបបិសាចតាមគក្កាឈើរប ពា កម្លាំងអស់នោះបានជ្រួតជ្រាប

Khmer Story Lovers



ពេញប្រាណឡើងដល់កំរិតលែងខ្លាចពិសពុលទាំងអស់ ។

ព្រោះហេតុនេះហើយបានជានាយអាចផឹកស្រាពិសធ្វើព្រងើយ, មុនដំបូងនាយឈឺចាប់ចង្អិតចង្អួល លុះចំរើនកម្លាំងរំលាយទៅ ជាតិពិសរឹតតែត្រឡប់ជាជួយនាយឲ្យរឹតតែខ្លាំងក្លាលើសដើម ។ នាយក្រេបស្រាពិសេសនៃអ្នកទាំងពីរ យូរទៅរឹតតែពិបាកចិត្តឡើង ខំហុចដើងផ្លូកសងគេវិញញាប់ដៃ ដើម្បីផ្គាប់ផ្គុន គេថែមទាំងអញ្ជើញគេផឹកស្រាកំដរខ្លួនផង ។ ចំណែកជនទាំងពីរស្មានថា មាណពចង់បបួលគេផឹកស្រាសាកល្បងកម្លាំងធាតុទៅវិញទេ, ហេតុនេះគាត់មិនព្រមចុះចាញ់ គោងខំត្រដរផឹកស្រាម្នាក់មួយក្រេបទៀត ។

ប៉ុន្តែនៅពេលស៊ុផលានត្រលៀសភ្នែក រគល្លួចលេបថ្នាំបន្សាបមួយគ្រាប់ម្នាក់ភ្លាម ។ មិនតែប៉ុណ្ណោះ គេសម្លឹងមុខមាណពឥតព្រិចភ្នែកស្មានថានាយលេបថ្នាំដែរ, តែមើលមិនឃើញសោះ គេទាំងគ្នាភាគញញើតជាខ្លាំងនឹកថា :

-យុវបុរសរូបនេះមានកម្លាំងធាតុច្រើនលើសលប់មិនដែលប្រទះមិនដែលឮនរណានិយាយសោះ ! អង់អាចក្លាហានម៉្លឹងៗតើគេចេញពីត្រកូលហងណាមក ?

ស៊ុផលានឥតដឹងគេយល់យ៉ាងណាទេ, នាយផឹកមួ[illegible]បហើយហុចឲ្យម្ចាស់គេវិញ ។ ជនកន្លាត់ទទួលឃ្លោកគ្រហមមកវិញសួរថា :

- ប្អូនប្រុសមានកម្លាំងស្តុកស្តម្ភយ៉ាងនេះ , ពួកយើងស្ងើចសរសើរណាស់, តើប្អូនមាននាមអីដែរ ?

- យី ! នឹកដល់រឿងនេះខ្ញុំឈឺក្បាលណាស់ ។ ឲ្យតែជួបមុខខ្ញុំ អ្នកខ្លះថាខ្ញុំត្រកូលស៊ុ, ចន្លុលខ្ញុំសួរឈ្មោះភ្លាម ។ ប៉ុន្តែតាមការពិតខ្ញុំគ្មានឈ្មោះគ្មានត្រកូលអីទេ ។ ពេលនេះខ្ញុំឆ្លើយនឹងអស់លោកមិនរួចទេ ! សុំទោស ។

ជនកន្លាត់នឹកថា អាច្រមក់មិនព្រមប្រាប់ឈ្មោះទេតើ !

គាត់សួរទៀត :

- ចុះលោកគ្រូប្អូនប្រុសមួយណាដែរ ? ជាក្រុមបក្សណា ?

-គ្រូខ្ញុំត្រកូលស៊ី ជាជូនចាស់ម្នាក់ ។ លោកមានជួបគាត់ទេ ? គាត់ជាអ្នកបង្កើតក្រុមព្រះអាទិត្យហើយខ្លួនខ្ញុំជាសិស្សច្បងជំនាន់ទីពីរ ។

ជនជាតិនិងស្ដុមនឹកព្រមគ្នា :

-អាល្អិតនិយាយផ្ដេសផ្ដាសណាស់ ! យើងស្គាល់ឈ្មោះក្រុមបក្សទាំងអស់ក្នុងពិភពលោកមិនដែលពុំថាមានក្រុមព្រះអាទិត្យព្រះចន្ទអីទេ, យាយចាស់ត្រកូលស៊ីចុកអីក៏មិនដែលពុំទៀត !

ជនកន្ទាត់មិនចង់ផឹកស្រាតទៅទៀតក៏ហុចឃ្លោកឲ្យនាយវិញពោលបន្ទប់ :

– អូ! ប្អូនប្រុសជាសិស្សច្បងជំនាន់ទីពីរនៃក្រុមព្រះអាទិត្យ ឬ ? អីចឹងបានជាពូកែអស្ចារ្យម្ល៉េះ ! សូមអញ្ជើញទៀតចុះ ។

ស៊ុផជានយល់ថាតាប៉ុនេះចូលចិត្តនិយាយតាល់តែរឿងផឹកស្រា ! ម្ល៉ោះហើយនាយវិតុកក្លាម :

– លោកមិនទាន់ពិសានៅឡើយ ។

ជនកន្ទាក់ក្រហមមុខ ដោយខ្មាសអៀនស្ងួរថ្ងបក្នាក់ :

– មែនឬ ?

តែក្នុងពោះខ្ញុំណាស់, គ្រាន់តែបន្ទូលងកាប្រមត់ជើងក្លាម ។ គាត់មិនទំកស្អានថាបារណាពចិត្តល្អស្មោះត្រង់មិនចង់ផឹកឲ្យញញ៉ាក់ឯងឯណា ! គាត់លបកប់ក្នុងពោះឃើញផឹកអស់ប្រាំបីក្រឡហើយ, ផឹកតទៅទៀតច្បាស់ជាទ្រាំទ្រមិនបានទេ ទោះមានថ្នាំបន្សាបក៏ដោយ ។

ហេតុនេះគាត់ធ្វើជាទទួលឃ្លោកស្រាលើកដាក់ក្បួនមាត់ហើយផឹកតែគាត់ខាំធ្មេញផ្គិតមិនឲ្យស្រាចូលទេ ជនសំគមមិនបានផឹកដែលក៏ធ្វើត្រាប់តាមគាត់ដែរ ។

ទីបំផុតបានសេចក្តីថា ស្រាដែលនៅសល់ក្នុងក្នុងពោះ ស៊ុផជានអស់ប្រាំពីរ ឬ ប្រាំបីភាគស្រេច ។ នាយមិនចេះផឹកស្រាផង បើក្នុំតែបានកម្លាំងកាយនៅក្នុងខ្លួនជួយទប់ទល់ ម្ល៉េះស្លាប់កាយហោងតាំងពីយូរណាស់ហើយ ។ ឥឡូវស្រាចូលដល់ពោះក្តៅង៉ំ នាយមិនតុលវែងជាគ្លាហានអង់អាចលើសដើម និយាយច្រើនឡើង ៗ រហូតបែករឿងកាស៊ីរ, ទីង ៗ តុង ៗ បារ៉ាហ... ជនទាំងពីរទំស្ដាប់ណាស់ដែរ តែឥតយល់អ៊ីសោះ ។

ជនកន្ទាត់នឹកថា:

– ថ្ងៃនេះបងប្អូនយើងពីរនាក់សាកល្បងកម្លាំងជាគុម៉ែ ៖ ក្មេងល្អិតល្អាចម្នាក់ឃើញថា អន់ណាស់ ។ បើរឿងនេះលេចពុំដល់ពិភពលោកច្បាស, ខ្មាសគេហើយដានហ្នឹង ។ ម្យ៉ាងទៀតបន្ទាប់ពីផឹកស្រាអាប្រមក់នេះបញ្ចេញ ដៃកាចសាហាវឥឡូវហើយ ! ពាក្យចាស់លោកថា «កើត

ជាកូនប្រុសត្រូវមានចិត្តអង់អាចក្លាហានមុះមុត» ។

គាត់នឹកសព្វគ្រប់ក៏មិចភ្នែកឲ្យសញ្ញាទៅគូកន ។ ជនសំគមយល់ភ្លាមលូកដៃក្នុងហោប៉ៅយកថ្នាំមួយគ្រាប់ចេញមករង់ចាំស៊ីផានប្រគល់ឃោកស្រាមកនឹងពេលលើកផឹកមួយក្អឹកហើកលូកដៃផ្លូតមាត់ឃោកលបទម្លាក់គ្រាប់ថ្នាំចូលផុត ក្រឡុកបន្តិចទើបសរសើរ :

– ស្រានេះផឹកយូរទៅកាន់តែឆ្ងាញ់ឡើង ។

ពេលដែលជនសំគមអនុវត្តគ្រោងការសម្ងាត់ ជនកន្ទាត់ក៏លូកយកថ្នាំមួយគ្រាប់លបដាក់ក្នុងឃោកគាត់ដែរ ។ ស៊ីផានមិនដឹងអីទេ, ស្មានថាខ្លួនជួបអ្នកប្រមឹកពីររូបនេះគិតតែស៊ីផឹកឲ្យបានសប្បាយម្ដង ។

ជនសំគមសម្រេចបំណងហើយបន្ទរថា :

–ប្អូនប្រុសអើយ, ផឹកអស់ស្រាហើយ បើចង់ពេកផឹកបន្ថើយកុះ ។

ស៊ីផានញញឹម :

–ល្អណាស់, បើលោកទាំងពីរមិនប្រកាន់ ខ្ញុំក៏ឥតប្រកែកដែរ ។

រាយលើកឃោកប្រុងអកទាំងអស់ ទទួលទឹកឃើញរៀងមួយក៏ស្មើ :

– កាលនៅទន្លេឈានកាង ខ្ញុំជិះទូកជាមួយចិន ១ គុង ១ឮគាត់ប្រាប់ថា បុរសនិងស្ត្រីកាលណាជួបគ្នាយល់ចិត្តគ្នាទៅវិញទៅមក , គេរៀបការជាប្តីប្រពន្ធ ។ បើសុទ្ធតែប្រុសវិញត្រូវសុំគ្នាធ្វើបងប្អូនធម៌ , អស់លោកមិនយល់ទាស់ទេឬ ? ចាំផឹកស្រាអស់ យើងសុំគ្នាធ្វើបងប្អូនធម៌ណា! ដើម្បីស្រួលផឹកស្រាជាមួយគ្នានៅពេលក្រោយកុំមសាច់កាំងទៀត ។ លោកទាំងពីរមានយោបល់យ៉ាងណាដែរ ?

ជនកន្ទាត់ខ្លាចម៉ាណាពមិនព្រមបង្ហើយស្រាក្នុងឃោក ក៏ប្រញាប់ឆ្លើយយល់ព្រមភ្លាម :

– ប្រសើរណាស់ , យើងឥតជំទាស់ទេ ! សុំប្អូនផឹកស្រានេះអស់សិនទៅ !

ស៊ីផានបែរទៅសួរជនសំគម :

– លោកបងខាងកោះមានយោបល់យ៉ាងណាដែរ ?

– បើប្អូនមានបំណងដូច្នេះខ្ញុំមិនជាចចិត្តបដិសេធទេ ។

ពេលនេះជាតិស្រាបានជ្រួតជ្រាបពេញខ្លួនហើយ, ស៊ីផានកែកាយសប្បាយក្អេចអ៊ីៗទាំងអស់ ។

នាយលើកស្រាក្នុងឃ្លោកទៀវបង្ហើយអស់រលីងតែម្ដងនេះមិនត្រដាក់ដូចមុនទេ ។ ជនកន្ទាក់ទះដៃផុងៗ :

– អស្ចារ្យ ! អស្ចារ្យ ! ឃ្លោកខ្ញុំសល់ស្រាទៀតនែ, ប្អូនប្រុស, ផឹកឲ្យអស់តែម្ដងទៅ ផឹកអស់សិនសឹមសុំគ្នាធ្វើបងប្អូន ។

ស៊ីផានត្រេកអរណាស់ ត្រូវស្រាកំដៅចិត្តគំនិតថែមផង នាយស្រវឹងបន្តិច តែកប្រាជ្ញអ្នកក្លេងក្លាងក្លាម ។ នាយទទួលឃ្លោកលើកអកស្រាអស់រលីងឥតសល់មួយតំណក់ ។ ជនទាំងពីរសម្លឹងមុខគ្នានឹកថា .

–ថ្នាំប្រាំបួនប្រាំបួន„ និងថ្នាំកំសួលភ្លើងមានពិសខ្លាំងលេខមួយក្នុងពិភពគុន ។ ថ្នាំប្រាំបួនប្រាំបួនដំរទៀងដោយជាតិពិសប៉ែតសិបមួយមុខ, ថ្នាំកំសួលភ្លើងក៏មិនអន់ដែរ, ឲ្យតែហ៊ានបោះមួយណាចូលក្នុងទឹកអណ្ដូងឬទឹកទន្លេតែមួយគ្រាប់, អ្នកស្រុកដែលប្រើទឹកនោះនឹងស្លាប់បង់ជីវិតអស់រយ ។ ពេលនេះយើងដាក់ថ្នាំទាំងពីរមុខហើយ, ប្រសិនបើមាណពនេះមិនស្លាប់ទៀត, ឃើញថាអស់ចំណេះហើយ ។

កំពុងតែគិតរៀងខ្លួនស្រាប់តែឮស៊ីផានស្រែកខ្លាំងៗ :

– អ៊ីយ៉ូយ ! យ៉ូយ… វីរហើយ… ខ្ញុំឈឺពោះណាស់ ។

គេឃើញនាយចំកោងខ្លួនឱបពោះជាប់ ។ ជនជាតិរ៉ាកមើលមុខគ្នាកនសើចញឹមៗ ។ ជនកន្ទាក់បន្ទឹងថា :

– ឈឺពោះឬ ? ប្អូនស៊ីសាច់ជ្រូកច្រើនពេកទេដឹង ?

– មិនមែនទេ.. អូយ…ឈឺណាស់…អូយ !

ស្រែកផង ស៊ីផានស្ទុះក្រោកក្អួតផង ។ ជនល្ងមនិងពាត់ស្ទុះក្រោកព្រមគ្នាដែរ ស្មានថានាយពុលប្រហារខ្លួនតាមទម្លាប់មនុស្សស្ពុលមជិតស្លាប់ ។ មិនតែប៉ុណ្ណោះគេបានចំរើនកម្លាំងទុកបង្ការផង, តែស៊ីផានយារដៃទះដើមឈើមួយក្បែរនោះអស់ទំហឹង ព្រមទាំងស្រែកខ្ទរខ្ទារ

– អូយ…អូយ ! ខ្ញុំ.. ឈឺណាស់ ។

មែននាយឈឺពោះខ្លួលខ្វាញ់ បាក់ដូចគេយកកាំបិតទៅកាប់ចិញ្ច្រាំពោះវៀនពោះតាំង និងថ្លើមប្រមាត់ឥតប្រណី ទោះខំចំរើនកម្លាំងធាតុទប់ទល់យ៉ាងណាក៏មិនបាត់ឈឺដែរ ព្រោះថ្នាំពិសទាំងពីរ

មុខមានឥទ្ធិពលខ្លាំងក្លាឥតគណនា បណ្តាលឲ្យនាយឈឺចាប់សឹងសន្លប់បាត់ស្មារតី ទៅជាគោក កញ្ឆក់កញ្ឆាំងដូចមនុស្សប្រកាច់ ។

ពេលឈឺចុកចាប់ម្តងៗ នាយលើកដៃកេះលើដើមឈើដូង ( ដាំង ) ហាក់ដូចជាស្រាលបន្តិច ម្ល៉ោះហើយនាយលើកដៃម្ខាងទៀតទះរឹបដាប់ទ្រូង, ការឈឺចាប់អន់ថយមួយកំរិតដែរ ។ កាលណានាយដកដៃចេញឈប់វាយនាយឈឺពោះរមួលខ្លួនទៀតទាល់តែគ្រវីគ្រវាត់ដៃជើង បញ្ចេញស្នៀតគុនគ្រប់បែបដែលបានហាត់លើកោះផ្សេងទៀតទើបធូរស្បើយ ។

ស្នៀតអស់នេះនាយចេះតែបញ្ចេញមកឥតក្បួនគម្រាមែន តែមានភាពកាចសាហាវក្រៃលែង ធ្វើឲ្យជនចាំងពីរសម្លឹងមុខគ្នាភ្លើភ្លឹកឡឹងឡង់ ហើយថយក្រោយមួយជំហានម្តងៗ ព្រោះគាត់ជឿជាក់ក្នុងចិត្តថាអ្នកខ្លាំងពូកែដូចកម្លោះនេះតែងក្លាយជាខ្លាកំណាចឬខ្លាត្រូវរបួស ក្នុងករណីដែលជាតិពិសធ្វើទុក្ខមុនពេលហៀបស្លាប់ ។ គេខ្លាចនាយចាប់បានក្រញាំហែកស៊ីដូចសត្វខ្លាទើបមិនហ៊ានទៅជិតដៃនាយទេ ។

ស៊ីផានលែងស្រែកលែងនិយាយ គិតតែបញ្ចេញស្នៀតគុនលាន់សន្ធឹកខ្យល់ហួៗគួរស្ញើប ។ ស្នៀតខ្លះដូចគុនជាវទានក្នុងចិត្តកកខ្លះដូចស្នៀតគុនរបស់ចិនមិនហួសបួន ខ្លះក៏ដូចស្នៀតម្ចាស់ក្តុំម៉ាងាន ឈ្មោះសៃយានទី...នាយវាយទះកាន់តែញាប់ កាន់តែដឹងជាក់ថា ការឈឺចាប់ធូរស្បើយតាមនោះជាលំដាប់ ហាក់ដូចកម្លាំងនាយនាំចេញមកហូរហៅ ។ ជនសំគមនិងកន្ទាត់សង្កេតឃើញស្នៀតគុននាយចាំងប៉ុន្មានចម្លែកពេកក៏នឹករៀងខ្លួនថា អាប្រមក់នេះប្រហែលជាសិស្សច្បងជំនាន់ទីពីរនៃក្រុមព្រះអាទិត្យអ៊ីគោនោះមែនហើយ, យើងមិនដែលឮមិនដែលឃើញទេ ។

ជនចាំងពីរនេះមានកម្រិតយុទ្ធសិល្បៈខ្ពង់ខ្ពស់ណាស់ គាត់មិនរវល់នឹងស្នៀតប្លែកៗប៉ុន្មានឡើយ គ្រាន់តែកោតសរសើរនិងស្ញប់កម្លាំងកាយមាណពតែមួយមុខគត់ប៉ុណ្ណោះ ។ កាលបើឃើញស៊ីផានវាយកាន់តែញាប់បញ្ចេញកម្លាំងកាន់តែច្រើនគេបែរមើលមុខគ្នាញញឹមខ្ញឹបនឹកថា :

- អាល្អិតនេះមានកម្លាំងស្ទុកស្ទម្ភតែគ្មានមូលដ្ឋានយុទ្ធសិល្បៈមាំមួនសោះ ។ ប្រសិនបើវាមិនស្លាប់ដោយសារថ្នាំពិសចាំងពីរមុខនេះយើងក៏មិនព្រួយទេ, វាមានតែកម្លាំងដូចដំរី...

អ្នកចាំងពីរគិតដល់នេះ ស្តាយស្រាថ្នាំព្រមចាំងថ្នាំពិសចាំងពីរគ្រាប់ជាខ្លាំងនឹកថា:

- បើដឹងដូច្នេះយើងវាយប្រហារវាតាំងពីដំបូងដៃហើយមិនបាច់ពឹងពាក់លើស្រាថ្នាំទេ !

ស៊ីផានហាត់គុកវិជ្ជាមួយសន្ទុះបាត់ឈឺពោះភ្លាមព្រោះជាតិពិសបាននាំគ្នាមកផ្តុំត្រង់បាត ដៃចាំងពីរ នាយដើរប្រុតប្រាតមកកែកន្ទក់ភ្លើងវិញពេលចាំងអស់បំណើប

– យើស, អម្បាញ់មិញឈឺពោះផល់ហើយ ! ខ្ញុំស្មានតែដាច់ពោះវៀនហើយតើ ! ខ្ញុំភ័យណាស់ ...

ជនសំគមនិងកន្ទាត់ភ្ញាក់ផ្អើលគិតភ័យ លាយឡំគ្នាដោយមិនស្មានថាក្នុងលោកនេះមានមនុស្សអាចទប់ទល់នឹងជាតិពិស គាត់ព្រមចាំងថ្នាំពីរបែបដ៏សាហាវដូចមាណពនោះ ។ ជនកន្ទាត់ផ្តើមសួរ :

– តឡូវឯងបាត់ឈឺពោះមែនឬ ?

– បាទ, បាត់ឈឺហើយ ។

នាយលូកដៃយកសាច់ជ្រូកដែលឆ្អិនខ្លោចលើកន្ទក់ភ្លើងឃើញបាតដៃមានស្នាមក្រហមប៉ុនគ្រាប់កាក់ នាយលាន់មាត់: យី ! ស្អីហ្នឹង ?

នៅបាតដៃក្មេងមានចំណុចខៀវតូចៗជាច្រើនទៀត គឺសុទ្ធជាជាតិពិសដែលតែមកផ្តុំគ្នាត្រង់បាតដៃមិនទាន់ចេញទៅណាអស់ព្រោះនាយមិនចេះប្រើកម្លាំងធាតុដំរុញពិស ។

ជនចាំងពីរយល់អាថ៌កំបាំងនេះយ៉ាងឆាយក៏ចូរស្រាលក្នុងចិត្តមួយអន្ទើនឹកត្រេកអរ :

– អាក្មេងនេះមិនចាំងចេះប្រើប្រាស់កម្លាំងធាតុផង យើងញញើតវាបានការអី ? វាមានកម្លាំងធាតុស្តុកស្តម្ភបែបនេះប្រហែលបានលេបថ្នាំទិព្វអ្វីដោយចៃដន្យទេដឹង ?

ស៊ីផានបន្ទឹវាថា :

– អម្បាញ់មិញយើងនិយាយគ្នាថាសុំធ្វើបងប្អូនធម៌ , តឡូវលោកខាងណាអាយុច្រើនជាងគេ , ហើយលោកឈ្មោះអីខ្លះ ?

គួរបញ្ជាក់ថាអម្បាញ់មិញជនស្គមនិងធាត់ជឿជាក់ថា មាណពតាយស្ទឹងដោយសារស្រាថ្នាំនិងជាតិពិសគាត់ដាច់ខាត ទើបយល់ព្រមធ្វើបងប្អូនធម៌ , តឡូវមាណពមិនស្លាប់សោះ គេជាអ្នកក្លាហានត្រូវការពាក្យសច្ចៈវៀងហូត ទោះមិនចង់ធ្វើបងប្អូនជាមួយក្មេងល្ងីល្ងើបែបនេះក្តី ។

កាលបើមិនអាចលេបពាក្យសំដីបានហើយ, ជនសំគមធ្វើជាក្អកខេះៗ :

–យើងឈ្មោះចាងសានអាយុច្រើនជាងប្អូនលីសៃខាងណេះៗ បើប្អូនឯងគ្មានឈ្មោះគ្មានត្រកូលអ៊ីចឹង

ម៉ែបងយើងអាច . .

ស៊ីផានប្រញាប់ឆ្លើយគាត់ :

-អ្នកគ្រូខ្ញុំដាក់ឈ្មោះថាស៊ីយ៉េតាវិផរណា ! ណេកបងទាំងពីរហៅខ្ញុំអ៊ីចឹងតាំងពីតូច ។

ផនសំគមសើចញឹមៗ :

- បើដូច្នេះយើងទាំងបីធ្វើជាបងប្អូនធម៌តាំងពីថ្ងៃនេះហើយណា !

ពោលហើយគាត់លុតជង្គង់លើកដៃប្រណម្យស្បថភ្លាមៗ :

- យើងឈ្មោះបារាំងសាន និងលើសស្រីព្រមទាំងស៊ីយ៉េតាវុទ្ធានទទួលគ្នាជាបងប្អូនធម៌ ។ ហ្នឹង តាំងពីថ្ងៃនេះទៅយើងទាំងបីត្រូវរួមសុខទុក្ខជាមួយគ្នា ។ បើក្បត់នឹងពាក្យសច្ចាសូមឲ្យគេយកដាវសោមកកាប់ដូចជ្រូកព្រៃនេះទៅ ? ហាស ! ហាស !

ផនគន្ធាត់សើចយកឈ្មោះផ្ទួសផ្ដាសមកប្រកាសប្រៀបអាត្មាទៅក្លាទេវតា ម្ល៉េះហើយគាត់បញ្ជាក់ថា « បារាំងសាន » មិនហ៊ានពោលពាក្យខ្ញុំទេខ្លាចបាញ់សប្បថ ។ ផនសំគមសើចឈ្មោះផ្ទួសផ្ដាសមួយដែរទើបលុតជង្គង់ប្រណម្យស្បថថា :

-បើស៊ី, បារាំងសាន និងស៊ីយ៉េតាវុទ្ធានសុំគ្នាធ្វើបងប្អូនធម៌ ។ ទោះបីយើងមិនកើតក្នុងខែតែមួយក៏សុខចិត្តស្លាប់ក្នុងថ្ងៃជាមួយគ្នាដែរ បើក្បត់នឹងពាក្យសច្ចាសូមឲ្យលើសស្រីត្រូវគេពិឃាតស្លាប់កាយហាក់ដូចជ្រូកព្រៃចុះហាសៗ...

ក្លកទាំងពីរគ្មានចិត្តសោះត្រង់សុំមាណពធ្វើប្អូនធម៌ទេ ។ ស៊ីផានទាំងលុតជង្គង់ប្រណម្យយ៉ាងផ្ចិតផ្ចង់ពោលពាក្យសច្ចា :

- បងទាំងពីរនិងរូបខ្ញុំជាបងប្អូនធម៌, មានស្រាមានសាច់ត្រូវចែកជូនបងទាំងពីរពិសាមុន ។ បើមានសត្រូវណាប៉ុនប៉ងសម្លាប់បងទាំងពីរខ្ញុំត្រូវជួយការពារឲ្យអស់សមត្ថភាព, បើមិនដូចសម្បថនេះទេ សូមទេវតាដាក់ទណ្ឌកម្មឲ្យខ្ញុំឈឺពោះរៀនកល់ថ្ងៃចុះ ។

ផនសំគមនិងគន្ធាត់ស្ដាប់ពាក្យសច្ចាដ៏ស្មោះត្រង់នេះដោយក្ដីរៀនខ្មាសរៀងខ្លួន ។ បន្ទាប់មកទើបផនគន្ធាត់ក្រោកឈរ:

- អ្នប្អូនទាំងបី, បងទាំងពីរ, មានការចាំបាច់ណាស់,សុំបែកគ្នាត្រឹមណេះសិន ។

## ខណ្ឌទី ២៣

# ក្នុងជំរំក្រុមខ្លាដែក

ស៊ីផាន់បើកភ្នែកធំៗ:

- លោកបងចង់អញ្ជើញទៅណាហ្នឹង ? អម្បាញ់មិញលោកបងបានមានប្រសាសន៍ថាយើងរួមសុខរួមទុក្ខជាមួយគ្នា... ខ្ញុំគ្មានរវល់កិច្ចការអីទេ, សុំទៅជាមួយបងទាំងពីរផង ។

ចាន់សានខ្ទាយសំណើចក្អាកក្អាយ :

- យើងទៅអញ្ជើញភ្ញៀវគ្មានអ្វីគួរឲ្យសប្បាយទេ, ប្អូនកុំទៅអី ។

ពោលចប់គាត់ងាកក្រោយដើរត្រួយផុតការិយាល័យ ។ ស៊ីផាន់ទើបបានមិត្តថ្មីៗខាយមិនទាន់ចិត្តបែកឃ្នាតគ្នាភ្លាមៗក៏តែតាមក្រោយគេស្រែក :

- ខ្ញុំសុំជូនដំណើរលោកបងបានឆ្ងាយបន្តិចផងដើម្បីរំលោះចិត្តនឹងព្រាត់គ្នា ព្រោះមិនដឹងថ្ងៃណា យើងបានជួបជុំផឹកស្រាស៊ីសាច់អាំងទៀតទេ ។

លីសៃសំគមឆ្មើមមុខមាំ ឥតខ្វល់រវល់នឹងឆ្ងាយទេ , ចាន់សានពោលសួរតាមក្រោយថា :

- នែប្អូនប្រុស , អ្នកត្រូវដាក់ឈ្មោះស៊ីផាន់ តែមុននោះប្អូនឯងឈ្មោះអីដែរ ? យើងជាបងប្អូននឹងគ្នាហើយ , មិនត្រូវលាក់នឹងបងៗទេណា !

មាណពអឹមទៀម :

- ខ្ញុំមិនលាក់ ហើយមិនហ៊ានកុហកបងទាំងពីរទេ ។ ប៉ុន្តែឈ្មោះខ្ញុំអាក្រក់ស្តាប់ពេកណាស់ , ម្តាយខ្ញុំហៅតែអាវ័ន្តផុតពូជតាំងពីតូចមក ។

ចាន់សានទ្រាំមិនបានសើចក្អាកក្អាយ :

- វ័ន្តផុតពូជ ! ហាស ៗ ...វ័ន្តផុតពូជ ! ឈ្មោះពីរោះក្រៃលែង !

ចាន់សាននិងលីសៃ បានបបួលគ្នាបោះជំហានមួយ ៗ តែគេបានលំដែងគុំសម្រាលខ្លួនដើរលឿនស្មើ, គ្រាន់តែមាណពឈប់ផុតជើងមើលគេទៅឆ្ងាយពីរបីព្យាមភ្លាម ។

(នៅមានត)

Khmer Story Lovers

ដកលំទុកតាមលេខ ៣៣៥ ចុះថ្ងៃទី ៣ ៦ - ៧០ ព្រះពុម្ពលើកទី ១ ចំនួន ២០០០ ក្បាល